**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
លេខ ២៨៤១ ព.ណ.ភ.ជ....

ថ្ងៃច័ន្ទ ៧កើត ខែស្រាពណ៍ ឆ្នាំរោងឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែសីហា ឆ្នាំ ២០២៤

# សេចក្ដីជូនដំណឹង

ក្រសួងពាណិជ្ជកម្ម មានកិត្តិយសូមជម្រាបជូនដំណឹងដល់ លោកអ្នកឧកញ៉ា អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី ដែលជាផលិតករ ឬអ្នកនាំចេញទោចក្រយាន ដែលបាននាំចេញ ឬមានបំណងនាំចេញទៅចក្រភពអង់គ្លេសឱ្យបានជ្រាបថា ប្រព័ន្ធអនុគ្រោះពន្ធ សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ (Developing Countries Trading Scheme-DCTS) របស់ចក្រភពអង់គ្លេស បានអនុញ្ញាតឱ្យប្រើវិធានបូកបន្ថែមក្នុងតំបន់ (Regional Cumulation) ដោយអាចយក «សម្ភារៈ ឬគ្រឿងបង្គុំទោចក្រយាន» ដែលមានដើមកំណើតនៅសាធារណរដ្ឋសង្គមនិយមវៀតណាម មកផលិតទោចក្រយាននៅព្រះរាជាណាចក្រកម្ពុជា។

សូមបញ្ជាក់ផងដែរថា ការប្រើប្រាស់ «សម្ភារៈ ឬគ្រឿងបង្គុំ» ដើម្បីផលិតទោចក្រយាន ត្រូវអនុលោមតាមលក្ខខណ្ឌតម្រូវ នៃវិធានដើមកំណើតទំនិញ ក្រោមប្រព័ន្ធអនុគ្រោះពន្ធ DCTS របស់ចក្រភពអង់គ្លេស។ ក្នុងន័យនេះ ដើម្បីទទួលបានដើមកំណើតទំនិញនៅប្រទេសកម្ពុជា ផលិតករ ឬអ្នកនាំចេញត្រូវប្រើ «សម្ភារៈ ឬគ្រឿងបង្គុំ» ដែលមិនជាប់កាតព្វកិច្ចពន្ធ (Duty-Free) ឬចំនួនកូតា (Quota-Free) ដូចមានចែងក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីចក្រភពអង់គ្លេស និងសាធារណរដ្ឋសង្គមនិយមវៀតណាម។

អាស្រ័យហេតុនេះ ផលិតករ ឬអ្នកនាំចេញទោចក្រយានទាំងអស់ ត្រូវជូនដំណឹងមកក្រសួងពាណិជ្ជកម្មនូវរាល់ការនាំចូល «សម្ភារៈ ឬគ្រឿងបង្គុំទោចក្រយាន» ពីសាធារណរដ្ឋសង្គមនិយមវៀតណាម ដើម្បីក្រសួងពិនិត្យផ្ទៀងផ្ទាត់អនុលោមភាព នៃវិធានដើមកំណើតទំនិញ។ ជាមួយគ្នានេះ ផលិតករ ឬអ្នកនាំចេញ ត្រូវធ្វើរបាយការណ៍ស្ដីពីការប្រើប្រាស់គ្រឿងបង្គុំទោចក្រយាននាំចូលពីសាធារណរដ្ឋសង្គមនិយមវៀតណាម (ដូចមានគំរូលិខិតស្នើសុំ និងគំរូរបាយការណ៍ជូនភ្ជាប់) មកកាន់អគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម។

ចំពោះព័ត៌មានលម្អិត សូមចូលគេហទំព័រ https://www.gov.uk/government/collections/trading-with-developing-nations ឬទំនាក់ទំនងមកលេខ ១២៦៦ / ០១២ ៩៤៨ ៤៨៤ / ០១២ ៨៣៣ ៣៩៧ / ០១៧ ៤៥៥ ៥១២ ឬតាមរយៈអ៊ីមែល dexim@moc.gov.kh។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម លោកអ្នកឧកញ៉ា អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី ជាផលិតករ ឬអ្នកនាំចេញទោចក្រយានទាំងអស់ ជ្រាបជាព័ត៌មាន។

សូមអរគុណ!

**ស្កេនដើម្បីទទួលបានព័ត៌មានលម្អិតអំពី ប្រព័ន្ធអនុគ្រោះពន្ធ សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍**

**ស្កេនដើម្បីទាញយក គំរូលិខិតស្នើសុំ និងគំរូរបាយការណ៍**